**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ**

# ការវិភាគរបស់នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃលើការគណនា ថ្លៃលក់អគ្គិសនីសំរាប់តំបន់ចែកចាយថ្មី របស់អគ្គិសនីកម្ពុជា នៅទីរួមខេត្តស្វាយរៀង

## ១-សេចក្តីផ្តើម

អាជ្ញាធរអគ្គិសនីកម្ពុជាបានទទួលលិខិតរបស់អគ្គិសនីកម្ពុជាលេខ៣៩៨៣លស-អក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤ ។ បន្ទាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យសំណុំឯកសារស្នើសុំកំណត់ថ្លៃលក់អគ្គិសនីនៅទីរួមខេត្តចំនួន៨ ដែលជាតំបន់ធ្វើសេវាកម្មថ្មីរបស់អគ្គិសនីកម្ពុជាមកឃើញថា ពត៌មានដែលអគ្គិសនីកម្ពុជាបានផ្តល់ឱ្យអាជ្ញាធរមានចំណុចមួយចំនួនពុំទាន់ច្បាស់លាស់ដែលអាចឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការវាយតម្លៃបាននៅឡើយ ។ ដើម្បីឱ្យការពិនិត្យនិងវាយតម្លៃ អាចដំណើរការបានឆាប់ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ អាជ្ញាធរអគ្គិសនីកម្ពុជាបានផ្ញើលិខិតទៅអគ្គិសនីកម្ពុជាស្នើផ្តល់ឯកសារបន្ថែម និងចាត់មន្ត្រីជំនាញមកពិភាក្សាគ្នានៅស្នាក់ការអាជ្ញាធរអគ្គិសនីកម្ពុជា ។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៥ អាជ្ញាធរអគ្គិសនីកម្ពុជានិងអគ្គិសនីកម្ពុជាបានបើកការប្រជុំពិភាក្សាស្តីពីការកំណត់ថ្លៃលក់អគ្គិសនីទាំង ៨ ខេត្ត ។ បន្ទាប់មកអគ្គិសនីកម្ពុជាបានរៀបចំឡើងវិញនិងស្នើសុំកំណត់ថ្លៃលក់អគ្គិសនីទាំង ៨ ខេត្ត ជាថ្មី តាមលិខិតលេខ ៦០២លស-អក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ។ ពត៌មាន ដែលអគ្គិសនីកម្ពុជាបានផ្តល់ឱ្យអាជ្ញាធរជាលើកទី២នេះ មានលក្ខណៈគ្រប់គ្រាន់និងសមស្របសំរាប់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការសិក្សានិងវាយតម្លៃបាន ។ <u>ដូច្នេះ នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ នៃអាជ្ញាធរអគ្គិសនីកម្ពុជា សូមធ្វើការវិភាគលើការគណនាថ្លៃលក់អគ្គិសនីនៅទីរួមខេត្តស្វាយរៀង ដែលជាតំបន់ទិញអគ្គិសនីពីប្រព័ន្ធអគ្គិសនីប្រទេសវៀតណាមមកចែកចាយដូចតទៅ :</u>

## ២-ការសង្កេតនិងវិភាគ

### ២.១- ទុនវិនិយោគ

- ទុនវិនិយោគស្មើនឹង **2,464,462** ដុល្លារអាមេរិច ។ ការវិនិយោគនេះមានទ្រង់ទ្រាយធំនិងមានតម្លៃខ្ពស់ បើប្រៀបធៀបទៅនឹងក្រុមហ៊ុនអគ្គិសនីឯកជនផ្សេងទៀត នេះសរបញ្ជាក់ឱ្យឃើញថាគុណភាពនៃមធ្យោបាយចែកចាយពិតជាល្អ ដូច្នេះ អាយុកាលរំលោះរបស់វាក៏វែងដែរ ។
- ការកំណត់អាយុកាលរំលោះ២៥ឆ្នាំសំរាប់ខ្សែបណ្តាញ អាជ្ញាធរអាចទទួលយកបាន ។

## ២.២- ការប្រាក់

អត្រាការប្រាក់ស្មើនឹង 3.5% ក្នុង១ឆ្នាំ គឺជាអត្រាមួយត្រឹមត្រូវយោងតាមកិច្ចព្រមព្រៀងខ្ចីបន្តរបស់អគ្គិសនីកម្ពុជាជាមួយរាជរដ្ឋាភិបាល ប៉ុន្តែអគ្គិសនីកម្ពុជាបានគណនាចំណាយការប្រាក់នេះលើទុនវិនិយោគសរុបដែលរួមមានប្រាក់កម្ចីនិងមូលធនផ្ទាល់ ស្មើនឹង 353,650,266 រៀល ។ ចំណាយការប្រាក់ដែលត្រឹមត្រូវគឺត្រូវគណនាលើប្រាក់កម្ចីសរុប បន្ទាប់ពីសាងសង់រួចដោយគិតរួមទាំងការប្រាក់ក្នុងពេលសាងសង់ ប៉ុន្តែមិនគិតបន្ថែមនូវមូលធនផ្ទាល់នោះទេ ។ ដូច្នេះ ចំណាយការប្រាក់ត្រឹមត្រូវស្មើនឹង 352,623,273 រៀល ក្នុងឆ្នាំ២០០៥ និងថយចុះជាលំដាប់នៅឆ្នាំបន្តបន្ទាប់ ។

## ២.៣- ទិន្នន័យផលិតកម្ម

តំបន់ធ្វើសេវាកម្មអគ្គិសនីនៅទីរួមខេត្តស្វាយរៀងរបស់អគ្គិសនីកម្ពុជាពុំមានផលិតកម្មខ្លួនឯងទេ គឺទិញអគ្គិសនីពីប្រព័ន្ធអគ្គិសនីប្រទេសវៀតណាមមកចែកចាយ និងគិតអត្រាបាត់បង់ថាមពលលើខ្សែបណ្តាញស្មើនឹង 11% ។ ចំណែកឯបន្ទុកប្រើប្រាស់នៅទីរួមខេត្តស្វាយរៀងក្នុងឆ្នាំ២០០៥ ស្មើនឹង 2,827,108 kWh អាជ្ញាធរអគ្គិសនីកម្ពុជាគិតថា ការព្យាករណ៍របស់អគ្គិសនីកម្ពុជាពុំគ្រប់គ្រាន់ទេ ពីព្រោះការព្យាករណ៍របស់អគ្គិសនីកម្ពុជាផ្អែកលើទិន្នន័យនិងការចុះស្រាវជ្រាវក្នុងឆ្នាំ២០០១ដែលនៅពេលនោះខ្សែបណ្តាញអគ្គិសនីពុំទាន់ល្អនៅឡើយ ។ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគិតថា បន្ទាប់ពីមានការរៀបចំខ្សែបណ្តាញអគ្គិសនីថ្មីក្រោមគំរោងឥណទានរបស់ ADB 1794-CAM (SF) នៅឆ្នាំ២០០៥ បន្ទុកប្រើប្រាស់នឹងកើនដល់ 3,550,000 kWh និងមានកំណើនបន្ទុកប្រើប្រាស់ 15% នៅកំឡុងឆ្នាំ២០០៦-២០០៧ ។

## ២.៤- ចំណាយផ្នែកផលិតកម្ម

ចំណាយទិញថាមពលស្មើនឹង 1,004,295,000 រៀល ក្នុងឆ្នាំ២០០៥ ។ ប៉ុន្តែអត្រាកម្រៃអាជ្ញាប័ណ្ណទិញថាមពលពីក្រៅប្រទេសត្រូវប្តូរពី 1.60 រៀល មក 1.50 រៀល ក្នុង១គីឡូវ៉ាត់ម៉ោងថាមពលទិញ ដែលជាអត្រាថ្មីសំរាប់អនុវត្តនៅក្នុងឆ្នាំការិយបរិច្ឆេទ២០០៥ តាមសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ ០១៣សរ-០៥-អអក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ។

## ២.៥- ចំណាយផ្នែកចែកចាយ

EDC គិតចំណាយលើបុគ្គលិកស្មើនឹង 204,354,257 រៀល ក្នុងឆ្នាំ២០០៥ សំរាប់បុគ្គលិកចំនួន ៣៨នាក់ ដែលមានប្រាក់ខែជាមធ្យមប្រហែលនឹង 122USD ក្នុង១នាក់ គឺមិនអាចទទួលយកបាន ។ អាជ្ញាធរអគ្គិសនីកម្ពុជា កំណត់យកអត្រាប្រាក់ខែជាមធ្យមស្មើនឹងអត្រាប្រាក់ខែផ្នែកផលិតកម្មក្នុងតំបន់ចែកចាយអគ្គិសនីដទៃទៀតរបស់អគ្គិសនីកម្ពុជាដែលមានចំនួនប្រហែលនឹង 95USD ក្នុង១នាក់ គឺស្មើនឹង 157,195,583 រៀល ក្នុងឆ្នាំ២០០៥ ។ ចំណែកឯចំណាយដំណើរការនិងការថែទាំ ស្មើនឹង 43,539,950 រៀល ក្នុងឆ្នាំ ២០០៥ អាចទទួលយកបាន ។ ប៉ុន្តែ ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ ស្មើនឹង 118,863,840 រៀល មានកំរិតខ្ពស់បើប្រៀបធៀបទៅនឹងសាខាអគ្គិសនីនៅខេត្ត កំពត តាកែវ បន្ទាយមានជ័យ..... ដែលមានអត្រា៣០រៀល/kWh នៃថាមពលលក់ ដូច្នេះ អាជ្ញាធរកំណត់យកអត្រា៣០រៀល/kWh គឺស្មើ

និង75,483,780 រៀល សំរាប់ខេត្តស្វាយរៀង និងអត្រាកម្រៃអាជ្ញាប័ណ្ណចែកចាយត្រូវប្តូរពី 1.10 រៀល មក 0.90រៀល ក្នុង១គីឡូវ៉ាត់ម៉ោងថាមពលលក់ ដែលជាអត្រាថ្មីសំរាប់អនុវត្តនៅក្នុងឆ្នាំការិយបរិច្ឆេទ២០០៥ តាមសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ០១៣សរ-០៥-អអក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ។

## ២.៦- ចំណាយផ្នែកហិរញ្ញវត្ថុ

EDCបានគិតចំណាយពន្ធអប្បបរមាស្មើនឹង 0.003 ដុល្លារ ក្នុង១គីឡូវ៉ាត់ម៉ោងផលិត គឺពុំត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធឡើយ ។ យោងតាមមាត្រា ២៤ នៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ចែងថា ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា១ភាគរយលើផលរបរប្រចាំឆ្នាំរួមទាំងពន្ធអាករនានា ។ ដូច្នេះ អាជ្ញាធរកំណត់តាមអត្រា១ភាគរយនេះ ។

ការគណនាបំណុលពិបាកទារ គឺផ្អែកលើការអនុវត្តន៍ប្រមូលចំណូលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ហើយកំរិតនៃបំណុលពិបាកទារនេះគឺជាចំនួនមួយដែលមិនអាចចៀសវាងបាន ឬអាចគណនាផ្អែកលើកំណើនឥណទេយ្យអតិថិជន (កំណើនប្រាក់ជំពាក់របស់អតិថិជន) ពីមួយឆ្នាំទៅមួយឆ្នាំ ។ ដោយសារអគ្គិសនីនៅទីរួមខេត្តស្វាយរៀងគឺជាតំបន់ធ្វើសេវាកម្មថ្មីរបស់ EDC ពុំមានប្រតិបត្តិការក្នុងឆ្នាំកន្លងទៅទេ ដូច្នេះ អាជ្ញាធរយកតួលេខដែលផ្តល់ដោយ EDC សំរាប់ការគណនាពេលនេះ ប៉ុន្តែត្រូវគិតអត្រា១ភាគរយនៃចំណូលពីការលក់ថាមពលប៉ុណ្ណោះ មិនមែនគិតលើចំណូលសរុបទេ ។ ដូចគ្នានេះដែរ សេវាធនាគារស្មើនឹង 2,000,000 រៀល ក្នុង១ឆ្នាំ អាចទទួលយកបានសំរាប់ការគណនាថ្លៃលក់អគ្គិសនីពេលនេះដែរ ។

អាជ្ញាធរពិនិត្យឃើញថា ថ្លៃភ្ជាប់ចរន្តមានកំរិតខ្ពស់នៅឆ្នាំដំបូង និងមានកំរិតទាបនៅឆ្នាំបន្តបន្ទាប់ទៀត ដូច្នេះ ដើម្បីចៀសវាងផលប៉ះពាល់ស្ថេរភាពហិរញ្ញវត្ថុ អាជ្ញាធរពុំយកថ្លៃភ្ជាប់ចរន្តមកសិក្សានៅពេលនេះទេ ។

## ៣-ការគណនាថ្លៃដើមអគ្គិសនី

ដោយផ្អែកលើការសង្កេតនិងកំណត់ខាងលើ ខ្ទង់ចំណាយទាំងឡាយរបស់អគ្គិសនីកម្ពុជានៅទីរួមខេត្តស្វាយរៀងសំរាប់គណនាចំណាយត្រឹមត្រូវក្នុងកំឡុងឆ្នាំ២០០៥-២០០៧ មានដូចខាងក្រោម :

| បរិយាយ | | | 2005 | 2006 | 2007 | សរុប |
|---|---|---|---|---|---|---|
| ១-ថាមពលទិញពីប្រទេសវៀតណាម | | គ.វ.ម៉ | 3,550,000 | 4,082,500 | 4,694,875 | 12,327,375 |
| ២-ថាមពលលក់ | | គ.វ.ម៉ | 3,159,500 | 3,633,425 | 4,178,439 | 10,971,364 |
| ៣-ចំណាយផ្នែកផលិតកម្ម | | | | | | |
| | ចំណាយទិញថាមពល | រៀល | 1,004,295,000 | 1,154,939,250 | 1,328,180,138 | 3,487,414,388 |
| | កម្រៃអាជ្ញាប័ណ្ណទិញថាមពលពីក្រៅ | រៀល | 5,325,000 | 6,123,750 | 7,042,313 | 18,491,063 |
| | ចំណាយផ្នែកផលិតកម្មសរុប | | 1,009,620,000 | 1,161,063,000 | 1,335,222,450 | 3,505,905,450 |

| | | | | | |
|---|---|---|---|---|---|
| ៤-ចំណាយផ្នែកចែកចាយ | | | | | |
| ចំណាយលើបុគ្គលិក | រៀល | 157,195,583 | 157,195,583 | 160,995,383 | 475,386,549 |
| ចំណាយដំណើរការនិងការថែទាំ | រៀល | 43,539,950 | 43,539,950 | 43,539,950 | 130,619,850 |
| ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ | រៀល | 75,483,780 | 105,677,297 | 147,948,216 | 329,109,293 |
| ចំណាយសំរាប់រំលោះអចលនទ្រព្យ | រៀល | 404,171,734 | 404,171,734 | 404,171,734 | 1,212,515,201 |
| ចំណាយការប្រាក់ | រៀល | 352,623,273 | 329,115,055 | 305,606,837 | 987,345,165 |
| កម្រៃអាជ្ញាប័ណ្ណចែកចាយ | រៀល | 2,843,550 | 3,270,083 | 3,760,595 | 9,874,227 |
| ចំណាយផ្នែកចែកចាយសរុប | | 1,055,159,090 | 1,046,295,154 | 1,043,427,661 | 3,144,881,905 |
| ៥-ចំណាយហិរញ្ញវត្ថុ | | | | | |
| ពន្ធនាំចូល | រៀល | 70,300,650 | 80,845,748 | 92,972,610 | 244,119,007 |
| ពន្ធអប្បបរមា | រៀល | 22,737,130 | 23,841,703 | 27,321,672 | 73,900,504 |
| បំណុលពិបាកទារ | រៀល | 20,536,750 | 23,617,263 | 27,159,852 | 71,313,864 |
| សេវាធនាគារ | រៀល | 2,000,000 | 2,000,000 | 2,000,000 | 6,000,000 |
| ចំណាយហិរញ្ញវត្ថុសរុប | | 115,574,530 | 130,304,713 | 149,454,133 | 395,333,376 |
| ៦-ចំណាយសរុប (៣+៤+៥) | | 2,180,353,620 | 2,337,662,867 | 2,528,104,244 | 7,046,120,731 |
| ៧-ថ្លៃដើមអគ្គិសនីក្នុង១គីឡូវ៉ាត់ម៉ោង (៦/២) | | **690** | **643** | **605** | **642** |

## ៤-ការវាយតម្លៃរបស់នាយកដ្ឋានជំនាញ

យោងតាមលទ្ធផលនៃការគណនាខាងលើ ថ្លៃដើមអគ្គិសនីក្នុងកំឡុងពេលបីឆ្នាំ (២០០៥-២០០៧) ស្មើនឹង **642** រៀល/kWh គឺជាថ្លៃដើមមួយសមរម្យអាចទទួលយកបាន ។

បើតាមយោបល់នាយកដ្ឋានជំនាញយល់ឃើញថា អគ្គិសនីកម្ពុជាស្នើសុំលក់ថ្លៃ **650**រៀល/kWh សំរាប់អ្នកប្រើប្រាស់ទូទៅ គឺជាថ្លៃលក់មួយអាចទទួលយកបាន បើប្រៀបធៀបទៅនឹងថ្លៃដើមអគ្គិសនី **642**រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ។ ដូច្នេះនាយកដ្ឋានជំនាញយល់ថា អាជ្ញាធរអគ្គិសនីកម្ពុជា គួរអនុញ្ញាត្ត និងឯកភាព ឱ្យអគ្គិសនីកម្ពុជាលក់អគ្គិសនីឱ្យតំបន់ចែកចាយថ្មីរបស់អគ្គិសនីកម្ពុជានៅទីរួមខេត្តស្វាយរៀង តាមអត្រា**៦៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង** ដែលបានស្នើសុំដោយអគ្គិសនីកម្ពុជា ហើយក៏ជាថ្លៃលក់មួយដូចថ្លៃលក់អគ្គិសនីនៅតំបន់ មេមត់ ក្រែក និង បាវិត ដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាមដូចគ្នា ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្នដែរ ។

ភ្នំពេញ, ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥

**ប្រធាននាយកដ្ឋាន**